**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តត្បូងឃ្មុំ**

លេខ...៤៦...សជណ.ម

ត្បូងឃ្មុំ ថ្ងៃទី...១៧...ខែ...កញ្ញា...ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
# ស្តីពី
# ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៦

សាលាខេត្តត្បូងឃ្មុំ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៦ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃ គ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**អ្នកទទួលការត្រូវបានបែកចែកជា៣ប្រភេទ៖**

- ប្រភេទទី១: អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អាគារ និងការងារបេតុង...។ល។)
- ប្រភេទទី២: អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដី ស ផ្លូវក្រួសក្រហម...។ល។)
- ប្រភេទទី៣:អ្នកទទួលការឯកទេស (អ្នកទទួលការមានឧបករណ៍ និងជំនាញបច្ចេកទេស សម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយ នៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ និងត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងទៅនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិចពីរគម្រោង ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើ លក្ខណៈវិនិច្ឆ័យ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេល និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការ ជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យសម្រេច ។

ករណីបើអ្នកទទួលការមានបំណងចង់ចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៦ សូមមកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគ នៃសាលាខេត្តត្បូងឃ្មុំ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោង៥.០០នាទី ល្ងាច ។ ចំពោះអ្នកទទួលការ ដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យសុំ ចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគ ដោយឥតបង់ថ្លៃ តាមអាស័យដ្ឋានក្នុងបរិវេណសាលាខេត្តត្បូងឃ្មុំ រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមអ្នកទទួលការទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងរួសរាន់មកដាក់ពាក្យ តាមកាលកំណត់ខាងលើកុំបីខាន។

**អភិបាលខេត្ត**

**ប្រាជ្ញ ចន្ទ**